លេខ ៥៣ ចេញផ្សាយថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែវិច្ឆិកា ឆ្នាំ២០២៥

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## មាតិកា


- ដំណើរទស្សនកិច្ចសិក្សារបស់ថ្នាក់ដឹកនាំ ន.ប.ធ. នៅទីក្រុងដាឡាត់ ខេត្តឡឹមដុង ប្រទេសវៀតណាម.................... ទំព័រទី១
- សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"..................... ទំព័រទី២
- សិក្ខាសាលាស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធសម្រាប់ការគ្រប់គ្រង, ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច"........ ទំព័រទី២
- កិច្ចប្រជុំលើការងារពាក់ព័ន្ធការចុះបញ្ជីពន្ធដាររបស់បរធនបាលរូបវន្តបុគ្គលឯករាជ្យតាមថ្នាលបច្ចេកវិទ្យាផ្លាស់ប្តូរទិន្នន័យកម្ពុជា.......... ទំព័រទី៣
- វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុសិង្ហបុរី ប្រចាំឆ្នាំ .................... ទំព័រទី៣
- សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយរបាយការណ៍ស្ថិរភាពហិរញ្ញវត្ថុអាស៊ាន+៣ ឆ្នាំ២០២៥"........................ ទំព័រទី៤
- វេទិកាហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពប្រចាំឆ្នាំ២០២៥ .................. ទំព័រទី៤
- សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"..................... ទំព័រទី៥
- កិច្ចប្រជុំតុមូលប្រចាំឆ្នាំស្តីពី "មូលនិធិរដ្ឋាភិបាលសកលប្រចាំឆ្នាំលើកទី១៨............................ ទំព័រទី៥
- សិក្ខាសាលាស្តីពី "ការដាក់ទណ្ឌកម្ម ខាងវិន័យចំពោះបុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ចដែលមិនអនុវត្តតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម"... ទំព័រទី៦
- សិក្ខាសាលាផ្សព្វផ្សាយស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពី "ទម្រង់របាយការណ៍សម្រាប់ភាពរឹងមាំហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបរធនបាល"............................ ទំព័រទី៦
- សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងប្រកាសចំនួនពីររួមមាន៖ "សេចក្តីព្រាងប្រកាសស្តីពីការបើកសាខារបស់បរធនបាល" និង "សេចក្តីព្រាងប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់បរធនបាល".. ទំព័រទី៧
- សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយ ផលិតផលឥណទានក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)"........................ ទំព័រទី៧
- ពិធីពិព័រណ៍ផ្សារភាគហ៊ុនកម្ពុជា "My First STOCK" ២០២៥............ទំព័រទី៨
- សិក្ខាសាលាផ្សព្វផ្សាយច្បាប់និងបទប្បញ្ញត្តិរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ"........................ ទំព័រទី៨


## ដំណើរទស្សនកិច្ចសិក្សារបស់ថ្នាក់ដឹកនាំ ន.ប.ធ. នៅទីក្រុងដាឡាត់ ខេត្តឡឹមដុង ប្រទេសវៀតណាម

ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** កាលពីថ្ងៃទី៣ ដល់ទី៥ ខែវិច្ឆិកា ឆ្នាំ២០២៥ អង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP-PIU1) នៃ **ន.ប.ធ.** ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំដំណើរទស្សនកិច្ចសិក្សានៅទីក្រុងដាឡាត់ ខេត្តឡឹមដុង ប្រទេសវៀតណាម។ ប្រតិភូទស្សនកិច្ចសិក្សាដែលដឹកនាំដោយ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានអង្គភាពអនុវត្តគម្រោង ACSEP សមាសភាគទី១ អមដោយ **លោក ឃុន វាសនា** អគ្គនាយករង និងជាប្រធានផ្នែកលទ្ធកម្ម, **លោក ប៉ូ សំអាង ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងជាប្រធានផ្នែកប្រតិបត្តិការ, លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច និងជាប្រធានផ្នែករដ្ឋបាលនិងគាំទ្រទូទៅ លោក ហេង សាមឌី អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងជាប្រធានផ្នែកតាមដានត្រួតពិនិត្យ អង្គភាពគ្រប់គ្រងគម្រោងនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** លោក/លោកស្រី ជាមន្ត្រីអនុវត្តគម្រោង និងទីប្រឹក្សា សរុបចំនួន ១១ រូប។ ទស្សនកិច្ចនេះមានគោលបំណងដើម្បីសិក្សា ស្រាវជ្រាវ ស្វែងយល់ និងដកស្រង់បទពិសោធន៍អំពីខ្សែច្រវាក់ផលិតកម្មកសិកម្ម ជាពិសេសលើផលិតផលបន្លែ ចាប់តាំងពីពេលចាប់ផ្តើមដាំដុះ ថែទាំ ប្រមូលផល ក្រោយពេលប្រមូលផល ការកែច្នៃ ការវេចខ្ចប់ ការផ្គត់ផ្គង់ទីផ្សារនិងការស្វែងយល់អំពីបញ្ហាប្រឈម និងដំណោះស្រាយដែលបានជួបប្រទះនាពេល



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

កន្លងមក។ល។ ក្នុងនោះក៏បានផ្តោតជាសំខាន់លើបទពិសោធន៍នៃការគ្រប់គ្រងខ្សែច្រវាក់ផលិតកម្ម ការវិវឌ្ឍន៍ខ្លួនពីផលិតកម្មជាលក្ខណៈគ្រួសារ ក្លាយជាក្រុមហ៊ុនផលិតកម្មដ៏ធំមួយ រចនាសម្ព័ន្ធក្រុមហ៊ុន ធនធានមនុស្ស ប្រភពទុនវិនិយោគ កិច្ចសន្យាទីផ្សារផែនការអាជីវកម្ម និងការប្រើប្រាស់បច្ចេកវិទ្យា នវានុវត្តន៍ក្នុងខ្សែច្រវាក់ផលិតកម្ម។ ប្រតិភូបានចុះទស្សនកិច្ចក្រុមហ៊ុនចំនួន២ រួមមាន ក្រុមហ៊ុន LANGBIAN FARM CO.,LTD និងក្រុមហ៊ុន PHONG THUY AGRICULTURAL PRODUCT TRADE MANUFACTURING CO., LTD ព្រមទាំងមជ្ឈមណ្ឌលប្រមូលផ្តុំ និងចែកចាយផលិតផលកសិកម្ម និងសហគ្រាសកែច្នៃមួយចំនួនទៀត ក្នុងទីក្រុងដាឡាត់ ខេត្តឡឹមដុង។



រូបភាព៖ ដំណើរទស្សនកិច្ចសិក្សារបស់ថ្នាក់ដឹកនាំ ន.ប.ធ. នៅទីក្រុងដាឡាត់ ខេត្តឡឹមដុង ប្រទេសវៀតណាម។

## សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"

នាព្រឹកថ្ងៃចន្ទ ៥ រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១០ ខែវិច្ឆិកា គ.ស.២០២៥ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យជាតិមានជ័យ បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ណី សាគល** អគ្គនាយករង នៃនិយ័តករបរធនបាលកិច្ច និង **លោក ជីវ សារិទ្ធ** សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យជាតិមានជ័យ នៅសាកលវិទ្យាល័យជាតិមានជ័យ។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ និងគុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យជាតិមានជ័យ។



រូបភាព៖ សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"។

## សិក្ខាសាលាស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធសម្រាប់ការគ្រប់គ្រង, ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច"

នាព្រឹកថ្ងៃចន្ទ ៥រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១០ ខែវិច្ឆិកា គ.ស.២០២៥ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), ក្រសួងមហាផ្ទៃ និងរដ្ឋបាលសាលាខេត្តកណ្តាល បានសហការរៀបចំសិក្ខាសាលាស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធសម្រាប់ការគ្រប់គ្រង, ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម ឧត្តមសេនីយ៍ឯក ខិន ចាន់ណារ៉ាល់** អគ្គនាយករងនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុនៃក្រសួងមហាផ្ទៃ និង **ឯកឧត្តម ឈុប ដារ៉ា** អភិបាលរងនៃគណៈអភិបាលខេត្តកណ្តាល នៅសាលាខេត្តកណ្តាល។ សិក្ខាសាលានេះត្រូវបានរៀបចំឡើង ដើម្បីបញ្ជ្រាបការយល់ដឹងបន្ថែមដល់សិក្ខាកាមពីក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមានពីការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ចអំពីដំណើរការបង្កើត ការចុះបញ្ជី និងប្រតិបត្តិការសកម្មភាពក្នុងក្របខណ្ឌបរធនបាលកិច្ចសង្គម។

កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់ មន្ត្រីជំនាញនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), តំណាងក្រសួងមហាផ្ទៃ និងរដ្ឋបាលសាលាខេត្តកណ្តាល និងតំណាងអង្គការ-សមាគមពាក់ព័ន្ធ។



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាព៖ សិក្ខាសាលាស្ដីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធសម្រាប់ការគ្រប់គ្រង, ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច"។

## កិច្ចប្រជុំលើការងារពាក់ព័ន្ធការចុះបញ្ជីពន្ធដាររបស់បរធនបាលរូបវន្តបុគ្គលឯករាជ្យតាមថ្នាលបច្ចេកវិទ្យាផ្លាស់ប្តូរទិន្នន័យកម្ពុជា

នាព្រឹកថ្ងៃពុធ ៧រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១២ ខែវិច្ឆិកា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច** និងសហការី បានចូលរួមកិច្ចប្រជុំលើការងារពាក់ព័ន្ធការចុះបញ្ជីពន្ធដាររបស់បរធនបាលរូបវន្តបុគ្គលឯករាជ្យតាមថ្នាលបច្ចេកវិទ្យាផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) ក្រោមការដឹកនាំរបស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** ដោយមានការចូលរួមពី **ឯកឧត្តមបណ្ឌិត តាំង ខ្វនលី** នាយក-ប្រតិបត្តិនៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" និង **លោក សេង ជាសិទ្ធ ប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហ-ប្រតិបត្តិការពន្ធដារអន្តរជាតិ** នៃអគ្គនាយកដ្ឋានពន្ធដារ នៅទីស្តីការ **អ.ស.ហ.**។



រូបភាព៖ កិច្ចប្រជុំលើការងារពាក់ព័ន្ធការចុះបញ្ជីពន្ធដាររបស់បរធនបាលរូបវន្តបុគ្គលឯករាជ្យតាមថ្នាលបច្ចេកវិទ្យាផ្លាស់ប្តូរទិន្នន័យកម្ពុជា។

## វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុសិង្ហបុរី ប្រចាំឆ្នាំ២០២៥

នាថ្ងៃពុធ-សុក្រ ៧-៩រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១២-១៤ ខែវិច្ឆិកា ឆ្នាំ២០២៥ ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក ហេង បញ្ញា ប្រធានការិយាល័យ** និង**លោក រិទ្ធ គីមហុង មន្ត្រីការិយាល័យគ្រប់គ្រងបរធនបាលកិច្ចសង្គមនិងបុគ្គលនៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច** និង**លោក ហឿន លីហួរ មន្ត្រីការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យានៃនាយកដ្ឋានកិច្ចការទូទៅ** មានកិត្តិយសត្រូវបានចាត់ឱ្យចូលរួម "វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុសិង្ហបុរី ប្រចាំឆ្នាំ២០២៥ (Singapore FinTech Festival 2025)" នៅប្រទេសសិង្ហបុរី ក្នុងគោលបំណងដើម្បីសិក្សាឈ្វេងយល់ និងដកស្រង់បទពិសោធន៍ពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ (Financial Technology-FinTech), បច្ចេកវិទ្យាម៉ាស៊ីនស្វ័យសិក្សា (ML) និងបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI), ក្របខណ្ឌបទប្បញ្ញត្តិ ឧត្តមានុវត្តន៍ បញ្ហាប្រឈម និងនិន្នាការថ្មីៗនៃការវិវត្តន៍ FinTech ជាសកល ក៏ដូចជាបច្ចេកវិទ្យាឌីជីថល ក្នុងការជំរុញការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជា។




រូបភាព៖ វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុសិង្ហបុរី ប្រចាំឆ្នាំ។

## សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយរបាយការណ៍ស្ថិរភាពហិរញ្ញវត្ថុអាស៊ាន+៣ ឆ្នាំ២០២៥"

នាព្រឹកថ្ងៃពុធ ១៤រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៩ ខែវិច្ឆិកា គ.ស.២០២៥, ដោយទទួលបានការចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** **ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយ



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

សហការី បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី"ការផ្សព្វផ្សាយរបាយការណ៍ស្ថិរភាពហិរញ្ញវត្ថុអាស៊ាន+៣ ឆ្នាំ២០២៥" នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ ។

សិក្ខាសាលានេះរៀបចំឡើងដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) សហការជាមួយ ធនាគារជាតិនៃកម្ពុជា (NBC) និងការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO) ក្នុងគោលបំណង ដើម្បីធ្វើការផ្សព្វផ្សាយរបាយការណ៍ និងប្រមូលផ្តុំអ្នកគាក់តែងគោលនយោបាយ អ្នកសេដ្ឋកិច្ច និងអ្នកជំនាញ ដើម្បីចូលរួមស្តាប់នឹងពិភាក្សាអំពីលទ្ធផលនៃរបាយការណ៍ និង ផលបច្ច័យសម្រាប់ប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា ព្រមទាំងពិភាក្សាពីវឌ្ឍនភាពថ្មីៗក្នុងវិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ព្រមទាំងឈ្វេងយល់ពីបរិយាបន្នហិរញ្ញវត្ថុអាចរួមចំណែកដល់ការពង្រឹងភាពធន់នៃវិស័យហិរញ្ញវត្ថុ។

សិក្ខាសាលានេះមានការចូលរួមពីតំណាងមកពីវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ធនាគារជាតិនៃកម្ពុជា (NBC) និងការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO) វិស័យធនាគារ និងវិស័យមិនមែនធនគារផងដែរ។




**រូបភាព៖** សាលាស្តីពី"ការផ្សព្វផ្សាយរបាយការណ៍ស្ថិរភាពហិរញ្ញវត្ថុអាស៊ាន+៣ ឆ្នាំ២០២៥"។

## វេទិកាហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពប្រចាំឆ្នាំ២០២៥

នៅថ្ងៃអង្គារ ១៣រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ស.ព. ២៥៦៩ ត្រូវនឹងថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ២០២៥, ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** **លោកស្រី ស៊ិន សុមាល័យ អនុប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច** និង**កញ្ញា ខុម សុវណ្ណលក្ខិណា មន្ត្រីបច្ចេកទេស** បានចូលរួមកម្មវិធី "វេទិកាហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពប្រចាំឆ្នាំ២០២៥ (IIF-Maybank Sustainable Finance Forum 2025)" នៅម៉ាឡេស៊ី ក្នុងគោលបំណងដើម្បីស្វែងយល់ និងដកស្រង់បទពិសោធន៍ពាក់ព័ន្ធនឹងក្របខណ្ឌបទប្បញ្ញត្តិ ឧត្តមានុវត្តន៍ បញ្ហាប្រឈម និងនិន្នាការថ្មីៗ នៃប្រព័ន្ធអេកូឡូស៊ីហិរញ្ញវត្ថុ ក្នុងការលើកកម្ពស់ហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព ព្រមទាំងការជំរុញការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជា។

កម្មវិធីនេះត្រូវបានសហការរៀបចំឡើងដោយវិទ្យាស្ថានហិរញ្ញវត្ថុអន្តរជាតិ (IIF) និងធនាគារ May Bank និងមានសិក្ខាកាមចូលរួមប្រហែល ១៥០ នាក់ មកពីស្ថាប័នរដ្ឋ និងស្ថាប័នឯកជនទាំងក្នុងតំបន់ និងអន្តរជាតិ។



**រូបភាព៖** វេទិកាហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពប្រចាំឆ្នាំ២០២៥ ។

## កិច្ចប្រជុំរវាង ន.ប.ធ. ជាមួយសមាគមបរធនបាលកម្ពុជា

នារសៀលថ្ងៃសុក្រ ១ កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២១ ខែវិច្ឆិកា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញដឹកនាំកិច្ចប្រជុំជាមួយសមាគមបរធនបាលកម្ពុជា តំណាងដោយ **លោកបណ្ឌិត ព្រំ វិសុទ្ធ ប្រធានសមាគមបរធនបាលកម្ពុជា** និងថ្នាក់ដឹកនាំ សមាជិក-សមាជិកា នៃសមាគម ដើម្បីពិភាក្សាអំពីការងារពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច។ កិច្ចប្រជុំនេះបានផ្តោតជាសំខាន់លើការរៀបចំនិងការប្រព្រឹត្តទៅរបស់សមាគម, ផែនការយុទ្ធសាស្ត្រក្នុងការជំរុញការអភិវឌ្ឍវិស័យបរធនបាលកិច្ច, ការអភិវឌ្ឍផលិតផលថ្មីៗ និងការពង្រីកទីផ្សារ, ទិសដៅ និងផែនការសកម្មភាពការងារពាក់ព័ន្ធនឹងការងារអភិវឌ្ឍវិស័យបរធនបាលកិច្ច។

សូមបញ្ជាក់ផងដែរថា យោងតាម "យុទ្ធសាស្ត្រអភិវឌ្ឍវិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥" និយ័តករបរធនបាលកិច្ច បានផ្តួចផ្តើម និងជំរុញឱ្យមានការបង្កើតសមាគមបរធនបាលកម្ពុជា ដែលចាត់ទុកថាជាផែនការសកម្មភាពអាទិភាពរយៈពេលខ្លីក្នុងការគ្រប់គ្រង និងការអភិវឌ្ឍវិស័យបរធនបាលកិច្ច។ ដោយមានការចូលរួម និងគាំទ្រពីក្រុមហ៊ុនបរធនបាល ប្រតិបត្តិករបរធនបាល បរធនបាលរូបវន្តបុគ្គលឯករាជ្យ និងបុគ្គលពាក់ព័ន្ធផ្តល់សេវាក្នុងវិស័យ

បរធនបាលកិច្ច, សមាគមបរធនបាលកម្ពុជា (Cambodia Trustees Association) ត្រូវបានបង្កើត និងទទួលបានការចុះឈ្មោះក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គលនៅក្រសួងមហាផ្ទៃតាមរយៈប្រកាសលេខ ១២៦៤៨ ប្រក នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៥។ បន្ថែមពីនេះ បន្ទាប់ពីទទួលលិខិតស្នើសុំការការទទួលស្គាល់សមាគមបរធនបាលកម្ពុជា ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៥ របស់សមាគមបរធនបាលកម្ពុជា និងការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**, **ន.ប.ធ.** បានប្រកាសការទទួលស្គាល់ជាផ្លូវការសមាគមបរធនបាលកម្ពុជាក្នុងកម្មវិធីវេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥ កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥។



រូបភាព៖ កិច្ចប្រជុំរវាង ន.ប.ធ. ជាមួយសមាគមបរធនបាលកម្ពុជា។

## សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"

នាព្រឹកថ្ងៃសៅរ៍ ២ កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២២ ខែវិច្ឆិកា គ.ស.២០២៥ **ន.ប.ធ.** និងសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ចខេត្តកោះកុង បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាព **ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច និង **លោក ឈុំ គី នាយករងនៃសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច** នៅសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ចខេត្តកោះកុង។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធន-បាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ និងគុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ចខេត្តកោះកុង។



រូបភាព៖ សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"។

## កិច្ចប្រជុំតុមូលប្រចាំឆ្នាំស្តីពី "មូលនិធិរដ្ឋាភិបាលសកលប្រចាំឆ្នាំ លើកទី១៨

ចាប់ពីថ្ងៃព្រហស្បតិ៍ ១៥រោច ខែកត្តិក ដល់ថ្ងៃសុក្រ ១កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២០-២១ ខែវិច្ឆិកា ឆ្នាំ២០២៥ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**, **លោក ហេង សំអុល ប្រធានការិយាល័យសហប្រតិបត្តិការ** និងលោក **អ៊ឹម ច័ន្ទរដ្ឋា ប្រធានការិយាល័យបណ្តុះបណ្តាល និងផ្សព្វផ្សាយនៃនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ** ត្រូវបានចាត់ឱ្យចូលរួមកិច្ចប្រជុំតុមូលប្រចាំឆ្នាំស្តីពី "មូលនិធិរដ្ឋាភិបាលសកលប្រចាំឆ្នាំ លើកទី១៨ (18th Annual Global East Government Funds Roundtable)" នៅប្រទេសសិង្ហបុរី។

កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងជួបជុំវិនិយោគិនស្ថាប័ន និងអាជ្ញាធរហិរញ្ញវត្ថុប្រចាំឆ្នាំទូទាំងសកលលោក ដើម្បីឈ្វេងយល់ និងដកស្រង់បទពិសោធន៍ ក៏ដូចជាពិភាក្សាអំពីវិស័យហិរញ្ញវត្ថុ មូលនិធិវិនិយោគ បញ្ហាប្រឈម និងកាលានុវត្តភាពក្នុងការវិនិយោគនៅក្នុងវិស័យផ្សេងៗ ដែលរួមមាន៖ អត្រាការប្រាក់ ទីផ្សារមូលធន យុទ្ធសាស្ត្រវិនិយោគមូលនិធិ និងបែងចែកកញ្ចប់វិនិយោគរបស់រដ្ឋាភិបាល និងស្ថាប័នហិរញ្ញវត្ថុ មូលនិធិសោធនិវត្តន៍ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលវិនិយោគិនកំពុងជួបប្រទះក្នុងវិស័យហិរញ្ញវត្ថុ និងវិស័យសក្តានុពលនាពេលបច្ចុប្បន្នផ្សេងៗទាំងក្នុងតំបន់ និងអន្តរជាតិ។



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

កិច្ចប្រជុំខាងលើ មានការចូលរួមពីថ្នាក់ដឹកនាំ និងតំណាងមកពីធនាគារកណ្តាល អាជ្ញាធរសេវាហិរញ្ញវត្ថុ វិនិយោគិនស្ថាប័នក្នុងវិស័យសាធារណៈនិងឯកជន ស្ថាប័នហិរញ្ញវត្ថុ ព្រមទាំងអ្នកជំនាញសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមកពីបណ្តាប្រទេសក្នុងតំបន់ និងអន្តរជាតិ។




**រូបភាព៖** កិច្ចប្រជុំតុមូលប្រចាំឆ្នាំស្តីពី "មូលនិធិរដ្ឋាភិបាលសកលប្រចាំឆ្នាំលើកទី១៨។

## សិក្ខាសាលាស្តីពី "ការដាក់ទណ្ឌកម្ម ខាងវិន័យចំពោះបុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ចដែលមិនអនុវត្តតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម"

នាព្រឹកថ្ងៃចន្ទ ៤កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, **ន.ប.ធ.** បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងប្រកាសស្តីពី "ការដាក់ទណ្ឌកម្ម ខាងវិន័យចំពោះបុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ចដែលមិនអនុវត្តតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម" និងសេចក្តីព្រាងប្រកាសស្តីពី "ការដោះស្រាយវិវាទក្នុងវិស័យបរធនបាលកិច្ច" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**។

សេចក្តីព្រាងប្រកាសស្តីពី "ការដាក់ទណ្ឌកម្មខាងវិន័យចំពោះបុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ចដែលមិនអនុវត្តតាមច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម" មានគោលបំណងបង្កើនប្រសិទ្ធភាពអនុវត្តច្បាប់របស់ បុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច ពាក់ព័ន្ធនឹងសកម្មភាពការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ព្រមទាំងស្របតាមអនុសាសន៍របស់ក្រុមការងារហិរញ្ញវត្ថុ (FATF)។

ចំពោះសេចក្តីព្រាងប្រកាសស្តីពី "ការដោះស្រាយវិវាទក្នុងវិស័យបរធនបាលកិច្ច" ត្រូវបានរៀបចំឡើងក្នុងគោលបំណងធានាប្រសិទ្ធភាព និងសមធម៌ ក្នុងប្រតិបត្តិការបរធនបាលកិច្ច និងការផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ចដើម្បីលើកម្ពស់កិច្ចគាំពារវិនិយោគិនក្នុងវិស័យបរធបាលកិច្ច។

សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈនេះ មានការចូលរួមពីតំណាងក្រសួងយុត្តិធម៌ ក្រសួងពាណិជ្ជកម្ម ធនាគារជាតិនៃកម្ពុជា សមាគមបរធនបាលកម្ពុជា គណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម ក្រុមហ៊ុនបរធនបាល, ធនាគារពាណិជ្ជដែលជាប្រតិបត្តិករបរធនបាល ផ្តល់សេវាសុវត្ថិភាពឬរក្សាទុក, បរធនបាលរូបវន្តបុគ្គលឯករាជ្យ, ក្រុមហ៊ុនវាយតម្លៃ និងក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ព្រមទាំងអង្គភាព និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត។



**រូបភាព៖** សិក្ខាសាលាស្តីពី "ការដាក់ទណ្ឌកម្ម ខាងវិន័យចំពោះបុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ចដែលមិនអនុវត្តតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម"។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពី "ទម្រង់របាយការណ៍សម្រាប់ភាពរឹងមាំហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបរធនបាល"

នៅរសៀលថ្ងៃចន្ទ ៤កើតខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៥ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពី "ទម្រង់របាយការណ៍សម្រាប់ភាពរឹងមាំហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបរធនបាល" នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃ **ន.ប.ធ.** តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**។ សិក្ខាសាលានេះ ត្រូវបានរៀបចំក្នុងគោលបំណងដើម្បីបញ្ជ្រាបការយល់ដឹងបន្ថែមដល់ក្រុមហ៊ុន

ក្រុមហ៊ុនបរធនបាលដើម្បីស្វែងយល់ពីអំពីការរៀបចំ និងការដាក់របាយការណ៍សម្រាប់ភាពរឹងមាំហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបរធនបាលដែលទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាតពី **ន.ប.ធ.** សំដៅដល់ការធានាលើប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព សណ្ដាប់ធ្នាប់ របៀបរៀបរយ និងទទួលបានទំនុកចិត្តពីអ្នកចូលរួមក្នុងវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងតំណាងក្រុមហ៊ុនបរធនបាលដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត និងក្រុមហ៊ុនផ្ដល់សេវាសវនកម្មដែលទទួលបានការទទួលស្គាល់ពី **ន.ប.ធ.** ។



រូបភាព៖ សិក្ខាសាលាផ្សព្វផ្សាយស្ដីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្ដីពី "ទម្រង់របាយការណ៍សម្រាប់ភាពរឹងមាំហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបរធនបាល"។

## សិក្ខាសាលាពិគ្រោះយោបល់លើសេចក្ដីព្រាងប្រកាសចំនួនពីរ រួមមាន៖ "សេចក្ដីព្រាងប្រកាសស្ដីពីការបើកសាខារបស់បរធនបាល" និង "សេចក្ដីព្រាងប្រកាសស្ដីពីក្រមសីលធម៌វិជ្ជាជីវៈរបស់បរធនបាល"

នាព្រឹកថ្ងៃពុធ ៦កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច, និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្ដីព្រាងប្រកាសចំនួនពីរ រួមមាន៖ "សេចក្ដីព្រាងប្រកាសស្ដីពីការបើកសាខារបស់បរធនបាល" និង "សេចក្ដីព្រាងប្រកាសស្ដីពីក្រមសីលធម៌វិជ្ជាជីវៈរបស់បរធនបាល" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** ក្នុងគោលបំណងទទួលបានមតិយោបល់ ក៏ដូចជាធាតុចូលបន្ថែមពីភាគីពាក់ព័ន្ធ ជាពិសេសអ្នកអនុវត្តការងារផ្ទាល់ ដើម្បីឱ្យសេចក្ដីព្រាងប្រកាសទាំងពីរខាងលើកាន់តែមានលក្ខណៈពេញលេញ និងគ្រប់ជ្រុងជ្រោយសំដៅដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងទំនុកចិត្តពីអ្នកចូលរួមក្នុងវិស័យបរធនបាលកិច្ច។ សិក្ខាសាលាពិគ្រោះយោបល់នេះ មានការចូលរួមពីតំណាងក្រុមហ៊ុនបរធនបាល, ធនាគារដែលជាប្រតិបត្តិករបរធនបាលផ្ដល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក, បរធនបាលរូបវន្តបុគ្គលឯករាជ្យ, ក្រុមហ៊ុនវាយតម្លៃ និងក្រុមហ៊ុនផ្ដល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ព្រមទាំងអង្គភាព និងស្ថាប័នពាក់ព័ន្ធ។



រូបភាព៖ សិក្ខាសាលាពិគ្រោះយោបល់លើសេចក្ដីព្រាងប្រកាសចំនួនពីរ រួមមាន៖ "សេចក្ដីព្រាងប្រកាសស្ដីពីការបើកសាខារបស់បរធនបាល" និង "សេចក្ដីព្រាងប្រកាសស្ដីពីក្រមសីលធម៌វិជ្ជាជីវៈរបស់បរធនបាល"។

## សិក្ខាសាលាស្ដីពី "ការផ្សព្វផ្សាយ ផលិតផលឥណទានក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)"

នាព្រឹកថ្ងៃសុក្រ ៨កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៨ ខែវិច្ឆិកា គ.ស. ២០២៥ **ន.ប.ធ.** ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១ (ACSEP-PIU1) ក្នុងក្របខណ្ឌ **កសហវ** បានរៀបចំសិក្ខាសាលាស្ដីពី "ការផ្សព្វផ្សាយ ផលិតផលឥណទានក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)" សម្រាប់ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន នៅសណ្ឋាគារក្លាស់ស៊ី ខេត្ត-បាត់ដំបង ក្រោមអធិប់តីភាព **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1, **ឯកឧត្តម ហេង វន្នី** អភិបាលរងនៃគណៈអភិបាលខេត្តបាត់ដំបង, **ឯកឧត្តម ឃ្លោក នួយ** អភិបាលរងនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និង **ឯកឧត្តម គោស៊ុំ ម៉ុនសឿត** អភិបាលរងនៃគណៈអភិបាលខេត្តប៉ៃលិន។

កម្មវិធីនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអំពីសាវតារ និងបច្ចុប្បន្នភាពនៃគម្រោង ACSEP ជាពិសេសគោលនយោបាយឥណទាន បែបបទ និងនីតិវិធីក្នុងការរៀបចំស្នើសុំឥណទាននៃគម្រោង ACSEP ដែលជាឥណទានមានលក្ខខណ្ឌអនុគ្រោះ និងគាំទ្រដល់សហគមន៍កសិកម្ម និងកសិធុរកិច្ច ដល់សមាជិក-សមាជិកានៃសហគមន៍កសិករ ដែលស្ថិតនៅខេត្តបាត់ដំបង

ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន ដែលមានបំណងស្វែងរកហិរញ្ញប្បទាន ដើម្បីគាំទ្រ និងពង្រីកអាជីវកម្មរបស់ខ្លួន។

សិក្ខាសាលានេះ មានការចូលរួមដោយលោក/លោកស្រី តំណាងរដ្ឋបាលខេត្តបាត់ដំបង បន្ទាយមានជ័យ និងខេត្តប៉ៃលិន, សមាជិក/សមាជិកាសហគមន៍កសិកម្ម, មន្ត្រី និងទីប្រឹក្សារបស់គម្រោង ACSEP-PIU1, តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, តំណាងសាជីវកម្មធានាឥណទានកម្ពុជា (CGCC) និងក្រុមការងារគម្រោងមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន៖ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) និងធនាគារស្ថាបនា (Sathapana Bank)។

សូមបញ្ជាក់ជូនផងដែរថា គម្រោង ACSEP-PIU1 ត្រូវបានពង្រីកវិសាលភាពដល់កម្រិតទូទាំងប្រទេស ដែលខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន ជាខេត្តគោលដៅថ្មីបន្ថែម លើខេត្តគោលដៅទាំង ៦ ដែលមានស្រាប់។



**រូបភាព៖** សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយ ផលិតផលឥណទានក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)"។

## ពិធីពិព័រណ៍ផ្សារភាគហ៊ុនកម្ពុជា "My First STOCK" ២០២៥

នាព្រឹកថ្ងៃសុក្រ ៨កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥, ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច, **លោក យុន វាសនា** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីពិព័រណ៍ផ្សារភាគហ៊ុនកម្ពុជា "My First STOCK" ២០២៥ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ប៉ែន ធុន្លា** អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង **ឯកឧត្តម ហុង សុហួរ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃផ្សារមូលបត្រកម្ពុជា នៅផ្សារទំនើបអ៊ីអន ភ្នំពេញ (អ៊ីអន ១)។



**រូបភាព៖** ពិធីពិព័រណ៍ផ្សារភាគហ៊ុនកម្ពុជា "My First STOCK" ២០២៥។

## សិក្ខាសាលាផ្សព្វផ្សាយច្បាប់និងបទប្បញ្ញត្តិរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ"

នៅថ្ងៃព្រហស្បតិ៍ ៧កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៧ ខែវិច្ឆិកា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាត និងចាត់តាំងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច, **លោក សារី ពុធរង្សី ប្រធានការិយាល័យនីតិកម្មនៃនាយកដ្ឋានកិច្ចការគតិយុត្តនិង អធិការកិច្ច** នៃ **ន.ប.ធ.** បានអញ្ជើញចូលរួមជាវាគ្មិនក្នុង "សិក្ខាសាលាផ្សព្វផ្សាយច្បាប់និងបទប្បញ្ញត្តិរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ" ដែលរៀបចំដោយអគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** និងមានការចូលរួមពីតំណាងនិយ័តករ និងអង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.**, រដ្ឋបាលខេត្តស្ទឹងត្រែង, សាខាពន្ធដារខេត្តស្ទឹងត្រែង, ស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង ព្រមទាំងសិស្សនិស្សិតនៃសាកលវិទ្យាល័យបៀលប្រាយ ខេត្តស្ទឹងត្រែង និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត នៅសណ្ឋាគារស្មើពេជ្រ នៃស្ទឹងត្រែង។



**រូបភាព៖** សិក្ខាសាលាផ្សព្វផ្សាយច្បាប់និងបទប្បញ្ញត្តិរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ"។



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888